តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

# ពិធីផ្សព្វផ្សាយរបាយការណ៍ស្តីពីការបោះឆ្នោតជាតិឆ្នាំ ២០១៣ របស់អង្គការតម្លាភាពកម្ពុជា


លោក គុល ព្រាប

នាយកប្រតិបត្តិ

អង្គការតម្លាភាពកម្ពុជា

# សេចក្តីផ្តើម

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

- អង្គការតម្លាភាពកម្ពុជា (TIC) ក្រោមកិច្ចសហប្រតិបត្តិការជាមួយ បណ្តាញសម្ព័ន្ធ សុច្ចរិតភាព និងគណនេយ្យភាពសង្គម (CISA) មានការទទួលស្គាល់ដោយ គ.ជ.ប ឱ្យធ្វើការសង្កេត ទៅ លើ ដំណើរការនៃការបោះឆ្នោតថ្នាក់ជាតិនៅកម្ពុជា ដែលបានប្រព្រឹត្ត ទៅនៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៣។
- គម្រោងនេះ បានទទួល ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ពី វិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI)។ វិទ្យាស្ថានជាតិ NDI បាន ទទួលការគាំទ្រពីជំនួយដ៏សប្បុរសនៃទីភ្នាក់ងារ សហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)។

# វិធីសាស្រ្ត

- ការសង្កេតការណ៍ បែប សំណាក (SBO) វិធីសាស្ត្រត្រួតពិនិត្យការបោះឆ្នោតផ្អែកទៅសំណាកដែលតំណាងឱ្យការិយាល័យបោះឆ្នោត និងផ្តល់ព័ត៌មានសុក្រិត អំពីការប្រព្រឹត្តទៅនៃការបោះឆ្នោតនិងការរាប់សន្លឹកឆ្នោត
- អ្នកសង្កេតការណ៍បោះឆ្នោតអព្យាក្រឹត្យរបស់អង្គការតម្លាភាពកម្ពុជា ចំនួន ៩០៦ នាក់ បានសង្កេតការិយាល័យបោះឆ្នោតចំនួន ៨០៩ទូទាំងកម្ពុជា
- ការិយាល័យបោះឆ្នោតសំណាកត្រូវបានជ្រើសរើស ដោយចៃដន្យតំណាងឲ្យខេត្ត/ក្រុងក្នុងប្រទេសកម្ពុជា



តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

# បរិបទនៃការបោះឆ្នោត និង នយោបាយ

# បរិបទនៃការបោះឆ្នោត និង នយោបាយ

តម្លាភាពកម្ពុជា TRANSPARENCY INTERNATIONAL Cambodia

- ក្របខ័ណ្ឌច្បាប់:
  - ច្បាប់ស្តីពីការបោះ ឆ្នោត ជ្រើស តាំងតំណាងរាស្ត្រ (LEMNA) ត្រូវបាន អនុម័តនៅឆ្នាំ១៩៩៧ ដើម្បីគ្រប់គ្រងការបោះឆ្នោតសភាជាតិ
  - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីសារព័ត៌មាន និងច្បាប់ស្តីពីការជួបប្រជុំ ក៏មានសារៈសំខាន់ផងដែរនៅ ក្នុងដំណើរការបោះឆ្នោត

# បរិបទនៃការបោះឆ្នោត និង នយោបាយ

- អង្គការក្នុងស្រុកនិងអន្តរជាតិ ព្រមទាំងអ្នកឯកទេសផ្នែកការងារបោះឆ្នោតជាច្រើនបាន សម្តែងអំពីការព្រួយបារម្ភទាក់ទងទៅនឹងអព្យាក្រឹត្យភាព និងសមត្ថភាពរបស់ គ.ជ.ប :
  - មានទីតាំងស្ថិតនៅក្រោមក្រសួងមហាផ្ទៃ (MOI)
  - ពុំមានកញ្ចប់ថវិកាគ្រប់គ្រាន់ ឬ សិទ្ធិអំណាចផ្ទាល់ខ្លួនដាច់ដោយឡែក
  - មានតម្លាភាពតិចតួចក្នុងការជ្រើសរើសគណៈកម្មការ និង ដំណើរការប្រតិបត្តិការ
  - ការទទួលបានឯកសារ និងការចូលរួមរបស់សាធារណៈនៅក្នុងកិច្ចប្រជុំនានានៅមានកម្រិត
  - បញ្ជីឈ្មោះបោះឆ្នោតត្រូវបានដកចេញពីគេហទំព័រ គ.ជ.ប មួយថ្ងៃមុនការបោះឆ្នោត

# បរិបទនៃការបោះឆ្នោត និង នយោបាយ

តម្លាភាពកម្ពុជា TRANSPARENCY INTERNATIONAL Cambodia

- ការងាររៀបចំដំណើរការបោះឆ្នោតមិនត្រូវបានរៀបចំដោយ គ.ជ.បទាំងស្រុងនោះទេ
  - ការបែងចែកការងារឱ្យស្ថាប័នថ្នាក់ក្រុមប្រឹក្សាឃុំសង្កាត់នាំអោយមានទំនាស់ផលប្រយោជន៍ ដែលជាឱកាសសម្រាប់ការរំលោភបំពាន និង ភាពលម្អៀងនៅក្នុងការចងក្រងបញ្ជីបោះឆ្នោត
- ច្បាប់របស់កម្ពុជា មិនបានបង្កអោយមានភាពងាយស្រួលចំពោះប្រជាពលរដ្ឋដែលមិនរស់នៅជាអចិន្ត្រៃយ៍ នៅ ក្នុង ឃុំដែលពួកគេចុះឈ្មោះ
- ការខកខានក្នុងសម្រេចនូវការចុះបញ្ជីអត្រានុកូលដ្ឋាននិង ការការខកខានមិនបានផល់អត្តសញ្ញាណប័ណ្ណ ជូនដល់ប្រជាពលរដ្ឋកម្ពុជា

# បរិបទនៃការបោះឆ្នោត និង នយោបាយ

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

- គ.ជ.ប បានឱ្យដឹងថាក្រុមប្រឹក្សា ឃុំ បាន ផ្តល់ប័ណ្ណនេះ ជាង ៨០០.០០០ សម្រាប់ការបោះឆ្នោតឆ្នាំ២០១៣ ហើយក្នុងនោះចំនួន ២៧០.០០០ ត្រូវបានផ្តល់ជូននៅក្រោយការចុះឈ្មោះបោះឆ្នោត និង ពេលបោះឆ្នោត។
- សវនកម្មទៅ លើបញ្ជីឈ្មោះអ្នកបោះឆ្នោតមួយ ដែលត្រូវបានធ្វើឡើង ដោយ គ.ជ.ប, NDI និង  CAS បានបង្ហាញឱ្យឃើញថា:
  - ១០,៨% នៃប្រជាពលរដ្ឋ ដែល មានលក្ខខណ្ឌសមស្របគិតថាពួកគេត្រូវបានចុះឈ្មោះ បែរជាពុំមានឈ្មោះនៅក្នុងបញ្ជី និង ៧,៨% នៃអ្នកដែលពុំមានឈ្មោះនៅក្នុងបញ្ជី គឺជាអ្នកដែលបានធ្លាប់បោះឆ្នោតពីមុន
  - ១៨,៣% នៃឈ្មោះនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោត ពុំមានផ្ទៀងផ្ទាត់បាន (ដោយសារតែ  គេបានប្តូរទីលំនៅអចិន្ត្រៃយ៍ ស្លាប់  ឬ មិនច្បាស់លាស់)

# បរិបទនៃការបោះឆ្នោត និង នយោបាយ

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

- ការចុះឈ្មោះលើសចំនួន:
  - ឈ្មោះស្ទួនគ្នាទាំងស្រុងជាង ៨០.០០០ករណី (ឈ្មោះដូចគ្នា ថ្ងៃខែឆ្នាំកំណើត ដូចគ្នា និងភេទដូចគ្នា)




- ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមិនមានឯករាជ្យ ភាព និង មិនមានភាពស្មើគ្នា ក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ សម្រាប់ការឃោសនាបោះឆ្នោត
- COMFREL បានរកឃើញថាទឹកខ្មៅជ្រលក់ដៃអាចលាងជ្រះបានដោយងាយស្រួល

# បរិបទនៃការបោះឆ្នោត និង នយោបាយ

ត្លាភាពកម្ពុជា TRANSPARENCY INTERNATIONAL Cambodia

**បរិយាកាសនយោបាយ:**

·មានការកើនឡើងនូវចំណាប់អារម្មណ៍និងការចូលរួមពីសាធារណជនទូទៅ ជាពិសេស ពីសំណាក់យុវជន

·យុទ្ធនាការបោះឆ្នោតនេះមានការប្រកួតប្រជែងខ្លាំង

·ការវិលត្រឡប់របស់មេដឹកនាំគណបក្សប្រឆាំងទោះបីគាត់មិនអាចឈរឈ្មោះប្រកួតប្រជែង

·ការអនុម័តច្បាប់ដែលមានភាពលម្អៀងនយោបាយ ដូចជាសច្បាប់ស្តីពីការបដិសេធន៍ចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

·បរិយាកាសនយោបាយមានភាពតានតឹងនិងការធ្វើឲ្យមហាជនមានការភ័យខ្លាច ( សង្គ្រាមស៊ីវិល  ឬការរើសអើងជាតិសាសន៍ )

ត្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

# របកគំហើញ

# របកគំហើញ

- ការចាប់ផ្ដើមបើកការិយាល័យបោះឆ្នោត និងការរៀបចំដំណើរការបោះឆ្នោត
- ដំណើរការបោះឆ្នោត
- ការបិទ និងការរាប់សន្លឹកឆ្នោត
- បរិយាកាសទូទៅ

# របកគំហើញៈ ការចាប់ផ្តើមបើក និង ការរៀបចំ

- ជាទូទៅ ការិយាល័យបោះឆ្នោត បានចាប់ផ្តើមបើកទាន់ពេលវេលា ស្ទើរតែគ្រប់ហិបឆ្នោត ទាំងអស់ត្រូវបានបង្ហាញ មានបិតត្រាត្រឹមត្រូវ និងបង្ហាញជាសាធារណៈ
- ភ្នាក់ងារនយោបាយមានវត្តមានក្នុងពេលការចាប់ផ្តើមបើកការិយាល័យបោះឆ្នោត និងការរៀបចំដំណើរការបោះឆ្នោត



# របកគំហើញៈ ដំណើរការបោះឆ្នោត

- នៅការិយាល័យបោះឆ្នោតចំនួន ៦០% អ្នកបោះឆ្នោតមួយចំនួនដែលមានឯកសារ អត្តសញ្ញាណត្រឹមត្រូវ មិនអាចរកឈ្មោះរបស់ ពួកគេឃើញនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោត និងមិនអាចបោះឆ្នោតបាន
- គណបក្សនយោបាយ ឬ អង្គការសង្គមស៊ីវិល មិនត្រូវបានអនុញ្ញាតឲ្យយកបញ្ជីឈ្មោះបោះឆ្នោតទៅកាន់ការិយាល័យ នៅថ្ងៃបោះឆ្នោត



# របកគំហើញៈ ដំណើរការបោះឆ្នោត

- ការិយាល័យបោះឆ្នោតចំនួន២៥% បានអនុញ្ញាតិឲ្យ អ្នកដែលពុំមាន ឯកសារអត្តសញ្ញាណមួយចំនួន បានបោះឆ្នោត ដែលអាចបង្ករអោយ មានការលួចបន្លំឬការក្លែងបន្លំជំនួសអ្នកផ្សេង
- មានការិយាល័យបោះឆ្នោតចំនួន ៩៣% ដែលអ្នកបោះឆ្នោតបាន ប្រើប្រាស់ បណ្ណ ICEs



# របកគំហើញ៖ ដំណើរការបោះឆ្នោត

- មន្រ្តីការិយាល័យបោះឆ្នោតចំនួន៤% ពុំបានគូសឈ្មោះ អ្នកបោះឆ្នោតនៅលើបញ្ជីឈ្មោះបន្ទាប់ពីពួកគេបានបោះឆ្នោតហើយ
- ២,៧%នៃការិយាល័យបោះឆ្នោតទាំងនោះត្រូវគេសង្កេតឃើញថាទឹកខ្មៅជ្រលក់ដៃត្រូវបាន គេលាងចេញនៅក្នុងបរិវេណការិយាល័យបោះឆ្នោត



# របកគំហើញៈ ការបិទ និង ការរាប់សន្លឹកឆ្នោត

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

- ការរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោតចំនួន ៩៩% ត្រូវបានកត់ត្រាត្រឹមត្រូវ
- នៅតាមការិយាល័យបោះឆ្នោតចំនួន ១១% លទ្ធផលនៃការបោះឆ្នោត មិនត្រូវបានគេបិតជាសាធារណៈភ្លាមៗ
- នៅទូទាំងប្រទេស មានសន្លឹកឆ្នោត តែ១,៧% ប៉ុណ្ណោះដែលត្រូវបាន កំណត់ថា ជាសន្លឹកឆ្នោតមិនបានការ



# របកគំហើញ: ការបិទ និង ការរាប់សន្លឹកឆ្នោត

ត្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

- ជិត១០០% នៃអ្នកតំណាងគណបក្សនយោបាយបានចូលរួមក្នុង ដំណើរការរាប់សន្លឹកឆ្នោត




Q: Which political agents were present during the counting process?

# របកគំហើញ: ការបិទ និង ការរាប់សន្លឹកឆ្នោត

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

## ជិត១០០% នៃអ្នកតំណាងគណបក្សនយោបាយដែលមានវត្តមាន និង បានចុះហត្ថលេខា ទៅលើកំណត់ហេតុរាប់សន្លឹកឆ្នោត




Q: Percentage of party agents who were present that signed the count record

# របកគំហើញៈ ការបិទ និង ការរាប់សន្លឹកឆ្នោត



# របកគំហើញៈ ការបិទ និង ការរាប់សន្លឹកឆ្នោត

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia



# របកគំហើញៈ ការបិទ និង ការរាប់សន្លឹកឆ្នោត

## ការព្យាករណ៍ទៅលើលទ្ធផលសម្លេងឆ្នោត និងកម្រិតនៃភាពល្អៀងសម្រាប់គណបក្សប្រកួតប្រជែង នីមួយៗ

| ល.រ | គណបក្សនយោបាយ | ការបោះឆ្នោតសរុប | ភាគរយ | កម្រិតនៃភាពល្អៀង ៩៥% | ចន្លោះនៃ ភាពជឿជាក់របស់ វិធីសាស្ត្រ SBO |
|---|---|---|---|---|---|
| ១ | គណបក្សសញ្ជាតិខ្មែរ | ៧៩០ | 0,៥% | 0,១% | 0,៥% - 0,៦% |
| ២ | គណបក្សហ៊្វុនស៊ិនប៉ិច | ៥.៣៨៩ | ៣,៧% | 0,៤% | ៣,៣% - ៤,១% |
| ៣ | គណបក្សសាធារណៈរដ្ឋប្រជាធិបតេយ្យ | ៧៩៤ | 0,៥% | 0,១% | 0,៥% - 0,៦% |
| ៤ | គណបក្សប្រជាជនកម្ពុជា | ៧0.៦៨៧ | ៤៨,៩% | ១,៦% | ៤៧,៣% - ៥0,៤% |
| ៥ | គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | ៤៧៥ | 0,៣% | 0,១% | 0,២% - 0,៤% |
| ៦ | គណបក្សខ្មែរឈប់ក្រ | ១.0១៤ | 0,៧% | 0,១% | 0,៦% - 0,៨% |
| ៧ | គណបក្សសង្គ្រោះជាតិ | ៦៣.៩២៥ | ៤៤,២% | ១,៧% | ៤២,៥% - ៤៥,៩% |
| ៨ | គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ១.៦0៩ | ១,១% | 0,១% | ១,0% - ១,៣% |

# របកគំហើញ៖ ការបិទ និង ការរាប់សន្លឹកឆ្នោត



# របកគំហើញៈ បរិយាកាសទូទៅ

- ជាទូទៅ អ្នកសង្កេតការណ៍អាចប្រើប្រាស់ទម្រង់សង្កេតការណ៍ក្នុងអំឡុងពេលរៀបចំការបោះ ឆ្នោត ពេលបោះឆ្នោត និងពេលរាប់សន្លឹកឆ្នោត នៅតាមការិយាល័យបោះឆ្នោតទាំងអស់។
- នៅការិយាល័យបោះឆ្នោត ចំនួន ៩,៣% អ្នកសង្កេតការណ៍បានរាយការណ៍ឱ្យដឹងថា មន្ត្រីការិយាល័យបោះ ឆ្នោតដូចជាមិនយល់អំពីបទបញ្ញា និងនីតិវិធីនៃដំណើរការបោះឆ្នោតឡើយ។
- នៅក្នុងការិយាល័យបោះឆ្នោតចំនួន ១,៧% ប៉ុណ្ណោះ ដែលអ្នកសង្កេតការណ៍បានរាយការណ៍ អំពីការគំរាមកំហែងឬគាបសង្កត់ទៅលើអ្នកបោះឆ្នោត
- ការិយាល័យបោះឆ្នោតចំនួន ៤,៧% បានអនុញ្ញាតអ្នកគ្មានភារកិច្ច អាចចូលក្នុងការិយាល័យបាន
- អ្នកសង្កេតការណ៍របស់អង្គការតម្លាភាពកម្ពុជា បានរាយការណ៍អំពីឧបទ្ទវហេតុហេតុធ្ងន់ធ្ងរ ចំនួន១៥ ដែលពាក់ព័ន្ធទៅនឹងអំពើហិង្សា ភាពចលាចល ឬ ការធ្វើបាតុកម្ម នៅក្នុង ឬ ជុំវិញការិយាល័យបោះឆ្នោត។

# ក្រោយថ្ងៃបោះឆ្នោត

តម្លាភាពកម្ពុជា TRANSPARENCY INTERNATIONAL Cambodia

- សន្លឹកឆ្នោតសរុបដែលខុសគ្នា រវាងគណបក្សទាំង២ មានចំនួនត្រឹម ២៨៩.៧៩៣ សម្លេង
- គ.ជ.ប បាន បដិសេធចំពោះការស្នើសុំឲ្យលេខប័ណ្ណ ICE
- មានបណ្តឹងចំនួន ១៩ ដែលគណបក្សនយោបាយបានប្តឹងទៅកាន់ គ.ជ.ប។ គ.ជ.ប បានបដិសេធរាល់ ពាក្យបណ្តឹង ទាំងនោះ។
- ក្រុមប្រឹក្សាធម្មនុញ្ញបានបើសវនាការជាសាធារណៈ ចំនួន៤លើក ដើម្បីស៊ើបអង្កេតលើ កញ្ចប់សុវត្ថិភាព "ក"សម្រាប់ខេត្ត ក្រចេះ បាត់ដំបង សៀមរាប និងកណ្តាល។

ឧទាហរណ៍ កញ្ចប់សុវត្ថិភាព "ក" ត្រូវបានគេរកឃើញថាគ្មានសុវត្ថិភាព គ្រប់គ្រាន់។ ៨កញ្ចប់កញ្ចប់សុវត្ថិភាព "ក" ក្នុងចំណោម ១៣ ក្នុងខេត្តក្រចេះ ត្រូវបានគេរកឃើញថាចំហរ ហើយនិងចំនួន ៧ ក្នុងចំណោម ១២ នៃកញ្ចប់សុវត្ថិភាព "ក" នៅក្នុងខេត្តសៀមរាប ត្រូវបានគេឃើញរហែក ឬក៏មិនបានបិទ ត្រឹមត្រូវ។

# ក្រោយថ្ងៃបោះឆ្នោត

- គជបបានពិន័យមន្ត្រីបំរើការនៅការិយាល័យបោះឆ្នោតចំពោះកំហុស និងភាពមិនប្រុងប្រយ័ត្ន
- ក្រោយពេលការពិនិត្យរយៈពេល ១៧ថ្ងៃរួចមក បណ្តឹងចំនួន ១៥របស់គណបក្សសង្គ្រោះជាតិស្តីពីភាពមិនប្រក្រតីនៃការបោះឆ្នោត ត្រូវបានបដិសេធ ដោយក្រុមប្រឹក្សាធម្មនុញ្ញ (CC)
- សំណើរសុំធ្វើការបើក កញ្ចប់សុវត្ថិភាពនៅតាមការិយាល័យបោះឆ្នោតដទៃទៀតនិងការផ្ទៀងផ្ទាត់សន្លឹកឆ្នោតមិនត្រូវបានអើពើ
- គណបក្សសង្គ្រោះជាតិបានធ្វើការ តវ៉ា ឱ្យមាន ការស៊ើបអង្កេតឯករាជ្យមួយទៅលើភាពមិនប្រក្រតី និងលទ្ធផលបោះឆ្នោត តាមរយៈគណៈ កម្មការ ឯករាជ្យមួយ
- គណបក្សសង្គ្រោះជាតិ បានរៀបចំបាតុកម្មអហិង្សា នៅថ្ងៃទី ៧ ខែកញ្ញានេះ។ គ្មានអំពើហិង្សា ឬ ការប្រទូសរ៉ាយណាមួយត្រូវបានរាយការណ៍ទេ
- បាតុកម្មរបស់ គណបក្សសង្គ្រោះជាតិដែលបានធ្វើឡើងចាប់ ពី ថ្ងៃទី១៥ ដល់ ១៧ ខែកញ្ញានេះ បានមានបញ្ហាករណីអំពើហិង្សាខ្លះកើតឡើង (ម្នាក់ស្លាប់ និង របួសប្រមាណចំនួន ១០ នាក់)

# អនុសាសន៍

# អានុសាសន៍

- បន្តស៊ើបអង្កេត និងរកការពិតស្តីពីភាពមិនប្រក្រតី ព្រោះវាមានភាពចាំបាច់ ក្នុងការកែសម្រួលឡើងវិញទាំងស្រុងទៅលើប្រព័ន្ធបោះឆ្នោតនៅក្នុងប្រទេសកម្ពុជា
  - បង្កើត គណៈ កម្មាធិការស៊ើបអង្កេត និងកំណែទម្រង់ការបោះឆ្នោត ដោយមានការចូលរួមពី គណបក្ស នយោបាយ  អង្គការ សង្គមស៊ីវិលសំខាន់ៗ និងអ្នកត្រួតពិនិត្យការបោះឆ្នោត ព្រមទាំងក្រុម ការងារអន្តរជាតិដែលពាក់ព័ន្ធ សហការដឹកនាំដោយគណបក្សនយោបាយចម្បងៗទាំងនោះ ឬ អង្គការ ណាមួយដែលត្រូវបានប្រគល់សិទ្ធិជូន ដោយមានការឯកភាពពីគណបក្សនយោបាយ
  - គជប   ចាំបាច់ត្រូវលាតត្រដាង  ឯកសារ និង ទិន្នន័យទាំងអស់

# អានុសាសន៍

- ការត្រួត ពិនិត្យ ឡើង វិញ និងការកែសម្រួលទៅលើច្បាប់ស្តីពីការ បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងប្រសិនបើអាចគួរពិនិត្យកែសម្រួលឡើងវិញទៅលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ៖
  - គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត : គណៈកម្មការថ្មីមួយ ទទួល បន្ទុកការងារបោះឆ្នោតដោយឯករាជ្យ និងមានអាណត្តិតាមរដ្ឋ ធម្មនុញ្ញ គួរត្រូវបានបង្កើតឡើងដោយមានសិទ្ធិអំណាច យុត្តាធិការគ្រប់ជ្រុងជ្រោយ និងថវិកាសម្រាប់ធ្វើ ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ហើយមន្ត្រីសំខាន់ៗ គួរត្រូវបានជ្រើសរើស ប្រកបដោយតម្លាភាព និងមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់។
  - បង្កើតឱ្យមាននូវការចុះ ឈ្មោះ បោះឆ្នោត ដោយស្វ័យប្រវត្តិ តាមរយៈការចុះបញ្ជីអត្រានុកូលដ្ឋានមួយដែលមានសុពលភាព ឬ ត្រូវដកហូតការទទួលខុសត្រូវពីក្រុមប្រឹក្សាឃុំ ដែលមាននិន្នាការនយោបាយ និងមានភាពលម្អៀង ពីការ

# អានុសាសន៍

- ការត្រួត ពិនិត្យ ឡើង វិញ និងការកែសម្រួលទៅលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងប្រសិន បើ អាចគួរពិនិត្យកែសម្រួលឡើងវិញទៅលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ៖
  - ការពិនិត្យកែសម្រួលឡើងវិញទៅលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បញ្ចូលវិធានការ ចាំបាច់នានា ដើម្បីទប់ស្កាត់ការប្រើប្រាស់ធនធានរដ្ឋក្នុងយុទ្ធនាការបោះឆ្នោត។
  - តម្លាភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់គណបក្សនយោបាយ
  - ចុះបញ្ជីអត្រានុកូលដ្ឋាន និង ផ្តល់អត្តសញ្ញាណប័ណ្ណជូនដល់ប្រជាពលរដ្ឋគ្រប់រូប
  - ត្រូវលុបបំបាត់ចោលនូវការប្រើប្រាស់ប័ណ្ណ ICEs។ ក្រសួងមហាផ្ទៃគួរបង្កើតយន្តការមួយសម្រាប់ជំនួសអត្តសញ្ញាណប័ណ្ណដែលបាត់ ឬ ត្រូវបានគេលួច។

# អានុសាសន៍

- ធានាអោយមានយុត្តិធម៌និងសមធម៌ក្នុងការប្រើប្រាស់ប្រព័ន្ធសារព័ត៌មាន
- ម្ចាស់ជំនួយអន្តរជាតិគួរដាក់ កំណែ ទម្រង់ការបោះឆ្នោត ជាចំណុចដៅសំខាន់មួយ សម្រាប់រាជរដ្ឋាភិបាលកម្ពុជាអនុវត្តដើម្បីទទួលបានថវិកាជំនួយ។

# Join with us to fight corruption

TRANSPARENCY INTERNATIONAL Cambodia




**Website:** http://ticambodia.org/




**Facebook:** https://www.facebook.com/ticambodia

**Subscribe to our Youtube:**

**TI Cambodia**

